ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិសន្តិសុខសង្គម
ក្រុមប្រឹក្សាវេជ្ជសាស្ត្រ
លេខ:...១០/២២.....ប.ស.ស./ក.វ.ប.ស

# គោលការណ៍ធ្វើបច្ចុប្បន្នភាពលក្ខណៈវិនិច្ឆ័យមូលដ្ឋានសុខាភិបាលឯកជន ដែលបានស្នើសុំចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស.

## I. លក្ខខណ្ឌយោង

- ប្រកាសលេខ:០៣៤ អ.ប.ស/អ.ព ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការកែសម្រួលបែបបទ និងលក្ខខណ្ឌបច្ចេកទេសក្នុងការសុំបើក ឬបិទ សុំកែទ្រង់ទ្រាយ ឬប្តូរទីតាំង នៃសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន។
- ប្រកាសអន្តរក្រសួងលេខ:២៩១ក.ប/ប្រ.កចុះ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីកិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាល រវាងបេឡាជាតិរបបសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាល សម្រាប់ផ្នែកថែទាំសុខភាព ប្រការ៣ ចំនុច ៣.២ និង៣.៣។
- សេចក្តីសម្រេចស្តីពីការបើកមន្ទីរសម្រាកព្យាបាល ឬមន្ទីរពហុព្យាបាល។

## II. សេចក្តីត្រូវការ

ទីតាំងត្រូវសម្រេចដោយក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃ ប.ស.ស. ដោយឈរលើមូលដ្ឋានៈ

- តម្រូវការសេវាសុខាភិបាលប្រកបដោយគុណភាព សុវត្ថិភាព និងក្រមសីលធម៌វិជ្ជាជីវៈ។
- លើសសមត្ថភាពផ្តល់សេវារបស់មូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស.។
- រួមចំណែកជម្រុញការលើកកម្ពស់គុណភាពសេវាសុខាភិបាល។

## III. ចុះបញ្ជិកាសហគ្រាសគ្រឹះស្ថាននៅ ប.ស.ស.

គ្រប់មូលដ្ឋានសុខាភិបាលឯកជនដែលមានបំណងចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស. ត្រូវចុះបញ្ជិកាសហគ្រាសគ្រឹះស្ថាននៅ ប.ស.ស.។

ថ្ងៃសុក្រ ១២ កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមករា ឆ្នាំ២០២២
ជ.ក្រុមប្រឹក្សាវេជ្ជសាស្ត្រ
ប្រធាន

វេជ្ជ. ប៉ុក វណ្ណថាត

អាសយដ្ឋានអាគារលេខ ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ: ០២៣-៨៨ ២៤ ៣៤,០២៣ ៨៨ ១០ ១៥ ០២៣-៨៨ ១០ ១៦,០២៣ ៨៨ ០៤ ១៧
ទូរសារ: ០២៣ ៨៨ ២៦ ២៣, ប្រអប់សំបុត្រP.O.Box 70
Website: www.nssf.gov.kh